**BMI0163**

## សម្ភាសជាមួយឈ្មោះ មួង រី ភេទស្រី អាយុ៥៣ ឆ្នាំ
## មុខងារខ្មែរក្រហមៈ “ប្រជាជននៅក្នុងកងចល័ត”
## រស់នៅភូមិស្រះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០០:៤៨:៥៥
## ទំព័រ២៤

វណ្ណៈ : អញ្ចឹងថ្ងៃហ្នឹងថ្ងៃទី១៦ ខែ០៦ ឆ្នាំ២០១១ ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ម៉ោ ពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាណាមីងណាស់ ហើយខ្ញុំម៉ោភូមិឃុំមីងគឺចង់ដឹង ពីរឿងរ៉ាវដែលទាក់ទងនឹងអាងត្រពាំងថ្ម វាមានលក្ខណៈយ៉ាងម៉េច ប្រជាជនយើង លើកមានការលំបាកយ៉ាងម៉េច អត់បាយអត់ឃ្លានអត់ទឹក ឬមួយក៏គេដាក់ដែន ការណ៍យ៉ាងម៉េចនៅក្នុងសម័យហ្នឹងមីង?

រី : ចា៎!

វណ្ណៈ : អញ្ចឹងបទសម្ភាសន៍ខ្ញុំជាមួយមីងគឺចង់ដឹង យកទៅចងក្រងជាឯកសារយកទុកជាប្រវត្តិសាស្រ្តឲ្យក្មេងជំនាន់ក្រោយ បានដឹងបានឮ អញ្ចឹងមីងមិនថាអីទេ មីងអនុញ្ញាតឲ្យសួរហើយយកទៅសរសេរ?

រី : ចា៎!

វណ្ណៈ : បាទ!អញ្ចឹងខ្ញុំអរគុណមីង ។ អញ្ចឹងជាដំបូងខ្ញុំសុំសួរឈ្មោះមីងដែរ មីងឈ្មោះអីទៅ?

រី : ខ្ញុំឈ្មោះ មួង រី ។

វណ្ណៈ : មីងអាយុប៉ុន្មានហើយ?

រី : ៥៣ឆ្នាំ ។

វណ្ណៈ : គ្រួសារមីងឈ្មោះអីមីង?

រី : អោក ឡេក ។

វណ្ណៈ : អាយុប៉ុន្មានហើយគាត់?

រី : គាត់អាយុ៥៩ហើយ ។

វណ្ណៈ : ចុះមីងមានកូនទាំងអស់ប៉ុន្មាននាក់ដែរ?

រី ៖ កូន៦នាក់ ។

វណ្ណៈ ៖ ស្រីប៉ុន្មាន?

រី ៖ ស្រី២នាក់ ។

វណ្ណៈ ៖ ឪពុករបស់មីងឈ្មោះអីដែរ?

រី ៖ ឈ្មោះ ម៉ោង ពុត ។

វណ្ណៈ ៖ ម្ដាយ?

រី ៖ ម្ដាយឈ្មោះ ប៉ុន សារួន ។

វណ្ណៈ ៖ សព្វថ្ងៃគាត់ទាំងពីរនៅដែរឬក៏យ៉ាងម៉េច?

រី ៖ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ ៖ ស្លាប់ជំនាន់ណា?

រី ៖ ស្លាប់ក្រោយ៧៩ គាត់ស្លាប់បាន២០ឆ្នាំហើយ ។

វណ្ណៈ ៖ ចុះបងប្អូនបង្កើតមីងប៉ុន្មាននាក់ដែរ?

រី ៖ ខ្ញុំអត់មានបងប្អូនផង ខ្ញុំម្នាក់ឯង ។

វណ្ណៈ ៖ មានតែម្នាក់ឯង?

រី ៖ ចា៎!

វណ្ណៈ ៖ អូ្ហ! ស្រុកកំណើតមីងនៅណាដែរ?

រី ៖ នៅភូមិនេះឯង ភូមិស្រះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយជ័យ ។

វណ្ណៈ ៖ បាទ!កាលពីដើមខេត្តបាត់ដំបង?

រី ៖ ចា៎!ពីដើមខេត្តបាត់ដំបង ។

វណ្ណៈ ៖ ចុះកាលពីនៅតូចមីងបានរៀនសូត្រដែរ?

រី ៖ បានរៀន ។

វណ្ណៈ ៖ រៀនដល់ថ្នាក់ណាដែរ?

រី ៖ ខ្ញុំរៀននៅថ្នាក់ទី៧ ។

វណ្ណៈ ៖ អូ្ហ!រៀនបានច្រើន ។ មីងហេតុអីបានមីងឈប់រៀនត្រឹមថ្នាក់ទី៧?

រី ៖ អត់មានហេតុអីទេ កាលហ្នឹងសម័យរំដោះប៉ុល ពត ។

វណ្ណៈ ៖ សម័យសង្គ្រាម?

រី ៖ ចា៎!សម័យប៉ុល ពតចូលម៉ោនោះ ថ្ងៃ១៧ មេសា ។

វណ្ណៈ ៖ បាទ!អញ្ចឹងពីចន្លោះឆ្នាំ៧០ទម្លាក់សម្ដេចសីហនុហើយ មីងនៅរៀនដែរ? ឆ្នាំ៧០ សម័យទម្លាក់គ្រាប់បែក មីងនៅរៀនឬក៏ឈប់ហើយ?

រី ៖ ចា៎!នៅរៀន ។

វណ្ណៈ ៖ ចុះភូមិនេះមានទម្លាក់គ្រាប់បែកទេ?

រី ៖ មាន ។

វណ្ណៈ ៖ មានដែរ ប៉ុន្តែមីងនៅអាចរៀនបាន?

រី ៖ ចា៎!ខ្ញុំនៅរៀនតែព្រះនេត្រព្រះហ្នឹងឯង ។

វណ្ណៈ ៖ រៀននៅត្រឹមព្រះនេត្រព្រះ អត់ទាន់បានដល់ស្វាយទេ?

រី ៖ អត់ទាន់បានដល់ស្វាយទេ បើថ្នាក់៦បាននៅស្វាយ ដល់ថ្នាក់ទី៧ត្រឹមវិទ្យាល័យ ។

វណ្ណៈ ៖ ចប់ត្រឹមវិទ្យាល័យព្រះនេត្រព្រះ?

រី ៖ ចា៎!

វណ្ណៈ ៖ បាទ!អញ្ចឹងពេល៧៥ ខ្មែរក្រហមចូលក្នុងភូមិហ្នឹងតើគេជម្លៀសចេញ?

រី ៖ ខ្មែរក្រហមចូល ភូមិនេះអត់បានជម្លៀសទេ ។

វណ្ណៈ ៖ បាទ!នៅហ្នឹង?

រី ៖ ចា៎!នៅក្នុងភូមិ ។

វណ្ណៈ ៖ អញ្ចឹង៧៥ ពេលខ្មែរក្រហមចូលម៉ោគេឲ្យមីងទៅធ្វើអីទៅ?

រី ៖ ដល់សម័យប៉ុល ពតហើយហ្នឹង?

វណ្ណៈ ៖ បាទ!

រី ៖ ខ្ញុំចេញទៅធ្វើចល័ត ទៅកងចល័ត ។

វណ្ណៈ ៖ កាលនោះមីងអាយុប្រហែលប៉ុន្មានហើយ នៅកងចល័ត?

រី ៖ កាលនៅកងចល័តអាយុ១៧ឆ្នាំ ។

វណ្ណៈ ៖ កងចល័តហ្នឹងកងចល័តភូមិ ឬកងចល័តស្រុក ឬក៏កងចល័តតំបន់?

រី ៖ កាលលើកទី១គេឲ្យទៅចល័តភូមិយើងធម្មតា ។

វណ្ណៈ ៖ ចុះទី២?

រី ៖ ទី២ចល័តស្រុក ។

វណ្ណៈ ៖ ចល័តស្រុករហូតឬយ៉ាងម៉េច?

រី ៖ ចល័តស្រុករហូតដល់អាងត្រពាំងថ្មហ្នឹង ចល័តៗស្រុករហូត ។

វណ្ណៈ ៖ ចុះចល័តភូមិគេឲ្យធ្វើអីខ្លះ ចល័តភូមិ?

រី ៖ លើកប្រពន្ធ័ប្រឡាយ លើកប្រព័ន្ធភ្លឺស្រែៗនៅឃុំរហាល់ ។

វណ្ណៈ ៖ ឃុំរហាល់?

រី ៖ ចា៎!

វណ្ណៈ ៖ អាហ្នឹងស្រុកព្រះនេត្រព្រះដែរ?

រី ៖ ចា៎!ស្រុកព្រះនេត្រព្រះ ។

វណ្ណៈ ៖ អាហ្នឹងគេលើកប្រពន្ធ័ភ្លឺស្រែហ្នឹងមានគ្នាប៉ុន្មាននាក់ទាំងអស់?

រី ៖ ច្រើនដែរ មិនដឹងថាប៉ុន្មានទេ ប៉ុនគេរួមសរុបទាំងអស់ក្នុងម៉ាឃុំ គេចែកដូចគ្នាដូចថាម៉ាភូមិៗចេះទៅចែកគ្នា ដឹងតែអ្នកលើករួមច្រើន ។

វណ្ណៈ ៖ បាទ!ដឹបូងៗអញ្ចឹងយើងនៅហូបបាយ ហូបអីបាន?

រី ៖ ចា៎!ហូបបាយបាន មិនទាន់ដាំនេះទេ មិនទាន់ដឹងថាបាត់ប៉ុន្មានទេ នៅអាចថាធ្វើមិនទាន់រាស់ម៉ែត្រគីបទេកាលមុនដំបូងបង្អស់ គ្រាន់តែគេបំបែកៗយើងពីម៉ែពីឪទៅ ។

វណ្ណៈ ៖ បាទ!៧៥ក្លាមហ្នឹង ពួក១៧មេសា គេជម្លៀសម៉ោឬនៅ? ឬនៅទេ?

រី ៖ ជម្លៀសម៉ោហើយ ពួកជម្លៀសម៉ោពីភ្នំពេញ ។

វណ្ណៈ ៖ បាទ!ជម្លៀសម៉ោបណ្ដើរៗហើយ?

រី ៖ ចា៎!ជម្លៀសម៉ោបណ្ដើរៗ ។

វណ្ណៈ ៖ អញ្ចឹងអ្នក១៧មេសា ជាមួយអ្នកភូមិនេះយើងធ្វើការរកចល័តជាមួយគ្នា?

រី ៖ ជាមួយគ្នា ។

វណ្ណៈ ៖ ហូបចុកជាមួយគ្នា?

រី ៖ ចា៎!ជាមួយ ។

វណ្ណៈ ៖ កាលហ្នឹងមានបែកចែកដូចថា គណៈសហករណ៍ ប្រធានកង ប្រធានអីនៅមឹងកាល ហ្នឹងមឹងអាចស្គាល់ខ្លះទេ?

រី ៖ ភ្លេចអស់ហើយកាលហ្នឹង ដឹងតែកាលមុនទៅគេរៀបមែន ប៉ុន្តែពួកគេហៅពួក សេនាជនកាលនោះពួកសេនាជន គេជាអ្នកកាន់កាប់អត់ទាន់មានរៀបចំពួកយើង គេ ។

វណ្ណៈ ៖ អ្ហូ!មុនដំបូងសេនាជនទេ?

រី ៖ ចា៎!ពួកសេនាជន គេកាន់កាប់រហូតកាលពួកខ្ញុំនៅរហាល់ហ្នឹង ។

វណ្ណៈ : ឈប សេនាជន?

រី : ទេ!គឺពួកកងសេនាជនហ្នឹង គឺពួកកងនារីៗដាច់ខាតដែលនៅក្នុងព្រៃនោះ ។ គេនៅជាមួយពួកខ្មែរក្រហមអញ្ចឹងទៅ ដល់គេចូលមកគេកាន់កាប់ពួកខ្ញុំ នៅភូមិហ្នឹងគឺអត់មានដាក់អ្នកណាទេគឺពួកសេនាជនទាំងអស់ កាលពីឆ្នាំ៧៥ ។

វណ្ណៈ : ចុះដល់ឆ្នាំណាបានមានប្រធានឃុំ ប្រធានភូមិប្រធានអីអញ្ចឹង?

រី : ឆ្នាំបន្ទាប់មកទៀត ចូលឆ្នាំទី២ ។

វណ្ណៈ : ៧៦អញ្ចឹង?

រី : ចាំ!៧៦ តែពេលនោះគេដាក់ហើយ ប្រធានភូមិតាមភូមិចេះគេដាក់ហើយ ។ ប៉ុន្តែពួកចល័តយើងខ្ញុំអត់ដឹងខាងក្នុងទេ ព្រោះខ្ញុំទៅចល័តដុតអស់ ក្នុងភូមិមិនដឹងយ៉ាង ម៉េចទេ តែប្រែប្រួល១៧មេសាភ្លាមៗ ពួកខ្ញុំគេជម្លៀសចេញទៅ ប៉ុន្តពួកនោះពួកចល័តគេនៅក្តាប់ គេម៉ោពីឆ្ងាយៗអត់ស្គាល់គេផង លែងហ៊ានមើលមុខគេទៀត ។

វណ្ណៈ : ចុះមីងមានដឹងទេថា ពេលខ្មែរក្រហមចូលក្នុងស្រុកភូមិដំបូងហ្នឹង តើពេលហ្នឹងគេមានផែនការណ៍ចាប់ទាហានលន់ ណុល ឬក៏ចាប់អ្នកស្រាវជ្រាវមន្ត្រីរាជការលន់ ណុល យកទៅសម្លាប់ឬនៅមីងថ្មីៗអញ្ចឹង?

រី : ចាំ!ថ្មីៗម៉ោដល់គេគ្រាន់ត្រសួររកប្រធានភូមិ កាលនោះមិនមានប្រធានភូមិគេហៅមេភូមិនោះ សម័យមេភូមិគេហៅសួររកទៅ គេគ្រាន់តែហៅទៅប្រជុំ ហៅទៅប្រជុំទៅប្រជាជនគេសួររកអ្នកមាន អ្នកក្រគេសួររកដូចថា អ្នកណាធ្វើទាហានធ្វើអីសួរ ប៉ុន្តែដូចថាភូមិនេះមិនសូវមានអ្នកណាធ្វើអីទេ ចេះតែចង់ថាជួយលាក់គ្នាខ្លះៗ ហើយអ្នកដែលគេចាប់បានយកទៅសម្លាប់ទៅអី អត់ដឹងថាគេចាប់បានពីណាពីណើបានទេ ព្រោះយើងបែកបាក់គ្នាអស់ ។

វណ្ណៈ : ចុះដូចជាគណៈភូមិភាគសម័យហ្នឹងមីងស្គាល់ទេ? តា ញឹមអីមីងដែលឮឈ្មោះទេ?

រី : ទេ!គ្រាន់តែឮឈ្មោះ មិនដែលឃើញមុខផងពួកហ្នឹង ។

វណ្ណៈ : បាទ!ចុះតាជា តាក្រុក តាអី ។

រី : តាក្រុក ឃើញ តាក្រុក គាត់ក្តាប់នៅឃុំនេះ នៅឃុំព្រះនេត្រព្រះនេះតាក្រុក បើតាជា តាញឹម អត់ដែលឃើញមុខមាត់គាត់ទេ មិនដឹងគាត់យ៉ាងណា ។

វណ្ណៈ : តាក្រុក តាមមីងធ្លាប់ឃើញធ្លាប់ដឹងតាមនៅតំបន់នេះ តើតាក្រុក គាត់កាចទេ?

រី ៖ តាក្រក គាត់អត់ដែលបានចុះដាប់ពួកខ្ញុំទេ គ្រាន់តែព្វឈ្មោះតាក្រក ពួកខ្ញុំដូចខ្ញុំប្រាប់ហើយពួកសេនាជនក្ដាប់ផ្ទាល់តែម្ដង ។

វណ្ណៈ ៖ បាទ!អញ្ចឹងមីងចល័តក្នុងភូមិបានរយៈប៉ុន្មានបានមីងទៅស្រុក?

រី ៖ ខ្ញុំចល័តភូមិទៅប្រហែលបានរយៈពេលមួយឆ្នាំ ។

វណ្ណៈ ៖ អញ្ចឹងមួយឆ្នាំ ចូល៧៦មីងទៅស្រុកហើយ?

រី ៖ ចាំ! ស្រុករហូតទាល់តែ ។

វណ្ណៈ ៖ នឹកស្រុក?

រី ៖ ចាំ!

វណ្ណៈ ៖ បាទ!ចល័តស្រុកហ្នឹងគេបញ្ជូនមីងទៅអាងត្រពាំងថ្ម?

រី ៖ ចាំ! ដល់ចល័តស្រុក ពេលណាយើងលើកទំនប់តាមប្រពន្ធ័ប្រឡាយតាមរហាល់រួចគេត្រឡប់ឲ្យចុះម៉ោប្រូតវិញ ប្រូតក្នុងឃុំយើងវិញ ប្រូតស្បូវប្រូតអីតាមគេប្រើ តាមរយៈពេលខែស្បូវក៏ស្បូវ ខែស្រូវក៏ស្រូវ ដល់ប្រូតរួចបានត្រឡប់ទៅអាងត្រពាំងថ្មនេះបានចាប់ផ្ដើមលើកអាងត្រពាំងថ្ម ។

វណ្ណៈ ៖ ឆ្នាំណាមីងទៅអាងត្រពាំងថ្ម?

រី ៖ មីងអត់ដឹងថាឆ្នាំណាផង ឆ្នាំពេលនោះមិនដែលគិតអីទេ ។

វណ្ណៈ ៖ ឥឡូវមីងគិតមើលថា ចប់ពីខ្មែរក្រហមចូល៧៥បានរយៈពេលប៉ុន្មានឆ្នាំ បានទៅអាងត្រពាំងថ្ម ។

រី ៖ រយៈពេលមួយឆ្នាំ ។

វណ្ណៈ ៖ អញ្ចឹង៧៦?

រី ៖ ចាំ!៧៦ហ្នឹងឯង កាលនោះមិនដែលមានអារម្មណ៍អីថាស៊ើបពេលវេលា ។

វណ្ណៈ ៖ អ្នកណាបញ្ជូនមីងទៅអាងត្រពាំងថ្ម?

រី ៖ បញ្ជូនទៅអាងត្រពាំងថ្ម ប្រធានភូមិយើងនេះឯង ប្រធានភូមិក្នុងភូមិនេះហើយ ។

វណ្ណៈ ៖ ចុះមីងចេញពីភូមិហើយ ទៅស្រុកហ្នឹង?

រី ៖ ពេលនោះគេហៅពួកមីងចុះមកប្រូតវិញ ដល់ប្រូតរួចគេមិនដែលឲ្យនៅភូមិទេ ប្រូតរួចប្រូតស្បូវ ដល់ពេលណាប្រូតស្បូវរួចគេបញ្ជូនឲ្យទៅវាល ទៅតែម្ដងអត់បានឲ្យចូលភូមិទេ ។

វណ្ណៈ ៖ ទៅអាងត្រពាំងថ្ម?

រី ៖ ចា៎!មិនដឹងអ្នកណាគេចាត់តាំងទេ គេហៅឲ្យទៅតែម្តង គេហៅទៅក៏ប្រជុំគ្នាទៅទាំងអស់តែម្តង ។

វណ្ណៈ ៖ ចុះអាងត្រពាំងថ្មហ្នឹង កាលមឹងទៅគេធ្វើដំណើរដោយដើរ ឬក៏មានឡាន?

រី ៖ ដើរអត់មានឡានទេ ដើរ ។

វណ្ណៈ ៖ ដើរចេញពីរហាល់ទៅរយៈពេលប៉ុន្មានបានទៅដល់?

រី ៖ កាលទៅដល់អាងត្រពាំងថ្មទៅម៉ោង៥-៦ល្ងាចហើយ ។

វណ្ណៈ ៖ ដើរចេញម៉ោងប៉ុន្មាន?

រី ៖ ដើរចេញទៅ ពេលដែលចេញពីភូមិនេះថ្ងៃប្រហែលម៉ោង៣ ប៉ុនទៅដេកៗនៅតាវ៉ូង១យប់ គេអត់ឲ្យទៅត្រង់នោះទេ ព្រឹកឡើងបានចេញម៉ោអាងត្រពាំងថ្ម ។

វណ្ណៈ ៖ ដំបូងចេញពី?

រី ៖ ដើរចេញពីនេះ គេហៅស្ពានអីនេះ ចេញពីវាលឈូកធំមដែលខ្ញុំនៅច្រូតស្រូវទៅបានទៅដល់ដំបូងល្ងាចៗនៅនោះឯង ។

វណ្ណៈ ៖ វាលឈូកអីគេ?

រី ៖ វាលឈូកធំមនោះ ដែលខ្ញុំនៅច្រូតស្រូវ ចេញពីវាលឈូកធំមទៅបានទៅអាងត្រពាំងថ្មតែម្តង ប៉ុនភ្លេចហើយ មិនដឹងថាទៅល្ងាចមិនដឹងទេ តែដឹងតែដើរវាស់ព្រឹក ។

វណ្ណៈ ៖ ដើរម៉ាយប់?

រី ៖ ចា៎!ដើរទាំងយប់ ដើរទាំងថ្ងៃនោះឯង ។

វណ្ណៈ ៖ ដើរប្រហែលជាមួយថ្ងៃដល់ទេ?

រី ៖ ចា៎!ដើរមួយថ្ងៃដល់ហើយត្រពាំងថ្ម ។

វណ្ណៈ ៖ បើថាពីព្រលឹមដល់យប់?

រី ៖ ទេ!មិនដល់យប់ទេ ។

វណ្ណៈ ៖ ពីព្រលឹមដល់ល្ងាច ដល់ទេ?

រី ៖ ចា៎!ពីព្រលលឹមដល់ល្ងាច ល្ងាចដល់ហើយ ដល់ពេលធ្វើដំណើរក៏យើងមិនបានលឿនប៉ុន្មានចាំគ្នីគ្នាទៅ ដើរធម្មតា ។

វណ្ណៈ ៖ តែមឹងមិនដឹងថាចំងាយប៉ុន្មានទេ?

រី ៖ អត់ដឹងទេ! ដូចថាវាងស្រពិចស្រពិលវាយូរ ។

វណ្ណៈ ៖ កាលហ្នឹងខែ បើខែខ្មែរយើងខែវស្សា ឬខែប្រាំងពេលមឹងចេញទៅ?

រី ៖ ខែប្រាំង មិនដឹងថាខែប៉ុន្មានអីប៉ុន្មាន ដឹងតែខែប្រាំង ។

វណ្ណៈ ៖ ពេលមីងទៅដល់អាងត្រពាំងថ្មហ្នឹង តើមីងឃើញសភាពយ៉ាងម៉េចដែរ មានមនុស្សនៅលើកហ្នឹងមុនហើយ ឬក៏មិនទាន់មានទេ?

រី ៖ អត់មានទេ មីងទៅដល់ឃើញដីវាលរាបធម្មតា មានតែវាលហើយនឹងព្រៃ ។

វណ្ណៈ ៖ អញ្ចឹងមីងទៅដល់ដំបូងអត់ទាន់មានមនុស្សលើកទេ?

រី ៖ ចា៎!អត់មានទេ ។

វណ្ណៈ ៖ ឃើញតែដីវាល?

រី ៖ ដីវាល ហើយនឹងព្រៃ ។

វណ្ណៈ ៖ ដល់អញ្ចឹងទៅប្រហែលប៉ុន្មានថ្ងៃ មានមនុស្សម៉ោច្រើនៗទៅ ប្រហែលរយៈពេល?

រី ៖ រយៈពេលដែលមីងទៅដល់ហើយនោះ ដល់ថ្ងៃនេះឮសួរមេក្រុគេចាក់លិចនោះ គេចាក់ហ្នឹងសួរគេថាពួកអ្នកខាងសេរីសោភ័ណខាងស្រុក ខាងខេត្តបន្ទាយមានជ័យយើង ប៉ុនគេចែកស្រុកគ្នា កាលហ្នឹងស្រុកសេរីសោភ័ណគេទៅមុន ពួកមីងពួកស្រុកព្រះនេត្រព្រះទៅដល់ខាងនោះ គេរៀបចំមេក្រុចាក់ហើយ គេចាក់ជាមេក្រុ ។

វណ្ណៈ ៖ គេចាក់ប្រកាសឲ្យទៅ?

រី ៖ ចា៎!គេចាក់ប្រកាសហៅគ្នាគេ ហៅក្រុមគេ ដល់ពួកខ្ញុំនេះខាងស្រុកព្រះនេត្រព្រះទៅបន្ទាប់ទៀត ប៉ុនមិនដឹងថាពួកណាទៅទៀតទេ ប៉ុនយើងដឹងតែមា៉ឌ័ណ្ឌៗ មា៉ស្រុកៗអត់មានថាចេញចូលទៅស្រុកនោះបាន ទៅស្រុកនេះបានទេ ដឹងតែយើងនៅស្រុកព្រះនេត្រព្រះនៅស្រុកព្រះនេត្រព្រះ អត់មានថាដើរទៅណាបានទេ អត់ដឹងទេៗថាអ្នកណាទៅពីខេត្តណាៗអត់ដឹងទេ ដឹងតែពេលកន្លែងពួកខ្ញុំនៅ ដឹងតែប៉ុនហ្នឹង ។ បើថ្ងៃណាពេលណាគេទៅអត់ដឹងទេ ព្រោះយើងនៅមា៉ឌ័ណ្ឌៗម្នាក់ អត់មានចង់ទៅលេងអ្នកនោះក៏បានៗអត់ទេ យើងនៅកន្លែងណានៅកន្លែងហ្នឹង ។

វណ្ណៈ ៖ ចុះមានប្រហែលជាប៉ុន្មានស្រុកទៅលើកនៅហ្នឹង?

រី ៖ មានស្រុកសេរីសោភ័ណ ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុកមិនដឹងស្រុកអីទៀតទេ ខ្ញុំចាំតែប៉ុនហ្នឹង ដឹងតែស្រុកសេរីសោភ័ណ ស្រុកព្រះនេត្រព្រះ ហើយនឹងស្រុកភ្នំស្រុកប៉ុនហ្នឹងឯង ដែលខ្ញុំចាំបាន ដូចថានៅជិតៗគ្នា ។

វណ្ណៈ ៖ មីងចាំបានតែ៣ស្រុកទេ?

រី ៖ ចា៎!ខ្ញុំចាំបានប៉ុនហ្នឹងឯង ។

វណ្ណៈ : ម៉េចបានមីងដឹងថាមានស្រុកសេរីសោភ័ណ ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុកអីអញ្ចឹង ម៉េចបានមីងដឹងអញ្ចឹង?

រី : ព្រោះដល់ពេលដែលលើកទំនប់ហើយមាំកន្លែងៗ គេបញ្ជូនបន្តទៅទៀតនោះ បញ្ជូនបន្តទៅទៀត ដូចខាងស្រុកសេរីសោភ័ណគេរួចមុនអញ្ចឹងគេទៅ ឃើញគេដើរលើខ្នងទំនប់ទៅ ដើររួចខាងយើងស្រុកព្រះនេត្រព្រះរួច គេបន្តទៅទៀតទៅដូចថា ម៉ាខ័ណ្ឌអញ្ចឹងឲ្យ ឧទាហរណ៍ថា ម៉ាគីឡូឬ២គីឡូដែលដាក់ឲ្យយើងលើករួចម៉ាស្រុកយើងអញ្ចឹងយើង លើករួចគេបន្តៗទៅទៀត ហើយនៅពេលកន្លែងណាមួយ ដែលត្រូវនៅ ខ្វះចន្លោះអញ្ចឹងគេ ប្រមូលគ្នាទាំងអស់ ទាំងប៉ុន្មានស្រុកប៉ុន្មាន លើកគ្រប់គ្នាឲ្យឆាប់ រួចបានជាដឹងថាស្រុក៣ ស្រុកហ្នឹងលើកជាមួយគ្នា ។

វណ្ណៈ : បាទ!ចុះមីងដូចថា មីងទៅដល់គេចែកដីឲ្យយើងវែក ភ្លាមហ្នងឬក៏គេឲ្យយើង សម្រាកអីសិន?

រី : ខ្ញុំមកដល់សម្រាកបានបាយថ្ងៃ ថ្ងៃទី១គេឲ្យទៅកាប់ឬស្សីយកមកធ្វើរោងនៅ ។

វណ្ណៈ : បាទ! កាប់ឬស្សីធ្វើរោងនៅ?

រី : ចា៎! កាប់ឬស្សី ។

វណ្ណៈ : ហើយថ្ងៃទី២?

រី : កាប់ឬស្សីរហូត ។

វណ្ណៈ : កាប់ឬស្សីបានប៉ុន្មានថ្ងៃ?

រី : បាន៣ថ្ងៃ សម្រាកផង កាប់ឬស្សីផង ៣ថ្ងៃហ្នឹងឯង ចំនួន៣ថ្ងៃ ។

វណ្ណៈ : កាប់ឬស្សី៣ថ្ងៃ ធ្វើរោងហើយបានគេចាប់ផ្តើម?

រី : ចា៎!បានគេចាប់ផ្តើម ។

វណ្ណៈ : ចាប់ផ្តើមវាស់ម៉ែត្រ?

រី : ចាប់ផ្តើមវាស់ម៉ែត្រគីប ។

វណ្ណៈ : ក្នុង១ម្នាក់ប៉ុន្មានម៉ែត្រគីប?

រី : មីងគេចាត់ទុកក្នុងកម្លាំងទី២ ចាប់ពី២ម៉ែត្រកន្លះ ។

វណ្ណៈ : កម្លាំងទី២ ២ម៉ែត្រគីប?

រី : ចា៎! ចាប់ពី២ម៉ែត្រគីបទៅ២ម៉ែត្រគីបកន្លះ ។

វណ្ណៈ : ចុះកម្លាំងទី១?

រី ៖ កម្លាំងទី១ មីងអត់ដឹងផង ។ ប៉ុនមីងឮគេនិយាយថាចាប់ពី៣ម៉ែត្រគីបកន្លះទៅ៤ម៉ែត្រគីប ។

វណ្ណៈ ៖ អ្ហូ! ច្រើន?

រី ៖ ចា៎! ច្រើន ក្លួយឯងទៅសម្ភាសន៍វាទៅ វាហ្នឹងកម្លាំងទី១ ។

វណ្ណៈ ៖ មីងដឹងទេថាហេតុអីបានជាគេមើលថា គេមើលយើងយ៉ាងម៉េចបាន គេបែងចែកថានេះកម្លាំងទី១ នេះកម្លាំងទី២គេមើលយើងយ៉ាងម៉េច?

រី ៖ គេមើលដូចថាយើង រាងសុខភាពវាមិនល្អទៅ យើងដូចថាមិនសូវមានកម្លាំងមាំមួនគេមើលដឹងថាអ្នកណាអ្នកកម្លាំង អ្នកមិនកម្លាំងគេមើលតាមហ្នឹងទៅ ។

វណ្ណៈ ៖ បាទ! ចុះពេលចាប់ផ្តើមវែកដីបូងអញ្ចឹង តើពេលហ្នឹងគេនៅឲ្យបាយយើងហូបធម្មតាឬក៏យ៉ាងម៉េចដែរ?

រី ៖ បាយគេវាល់ក្លួយ គេវាល់នឹងចានយើងអាចានចង្កេះហ្នឹង ។

វណ្ណៈ ៖ ហូបឆ្អែតដែរ?

រី ៖ អត់ឆ្អែតទេ ប៉ុនគេវាល់តែចានហ្នឹង ។

វណ្ណៈ ៖ ចុះក្នុងមួយថ្ងៃបានប៉ុន្មានពេល?

រី ៖ បាន២ដង ព្រឹកល្ងាច ។

វណ្ណៈ ៖ បាន២ដងទេ បាយវាល់ចែកគ្នា មួយចានចង្កេះ?

រី ៖ ចា៎! មួយចានចង្កេះ ។

វណ្ណៈ ៖ អញ្ចឹងអត់បានឆ្អែតទេ?

រី ៖ អត់ឆ្អែតទេ ប៉ុនសម័យនោះទោះបីជាយើងមិនឆ្អែតក៏អត់ហាននិយាយថា អត់ឆ្អែតដែរត្រូវតែឆ្អែត ទោះបីជាពិបាកយ៉ាងណាក៏ថាសប្បាយដែរ ។

វណ្ណៈ ៖ អញ្ចឹងប្រសិនជា បើយើងធ្វើការខ្លាំងហើយហូបបាយអត់ឆ្អែតអញ្ចឹងមិនបាក់កម្លាំង ស្លាប់មានមនុស្សស្លាប់?

រី ៖ បាក់ មានៗមនុស្សស្លាប់ ប៉ុនបើស្លាប់ទៅគេយកទៅពេទ្យទៅ ឧទាហរណ៍ថា ឈឺទៅគេយកទៅពេទ្យ តែស្លាប់រស់យើងអត់ដឹងបើគេមិនឲ្យយើងឃើញ គេយកទៅកន្លែងពេទ្យបាត់ មានអ្នកបាក់កម្លាំងអ្នកឈឺអ្នកអីដេកពេទ្យច្រើនណាស់ គ្រាន់តែគេយកទៅក៏យកទៅ តែយើងនេះមិនហ៊ានដូចថា ទៅសួរសុខទុក្ខគ្នាមិត្តភក្រអីខ្ញុំមិនហ៊ានទេ ។

វណ្ណៈ ៖ តែភាគច្រើនអ្នកដែលឈឺអញ្ចឹងប្រហែលជាស្លាប់?

រី : ចា៎! មិនដែលឃើញបានមកជួបគ្នាវិញ មិនដឹងគេទៅណា មិនដឹងថាគេជម្លៀសគ្នាទៅណាក៏ខ្ញុំមិនបានដឹង មិនបានឃើញ ជួនកាលក៏ឃើញម៉ោវិញទៅ ជួនកាលមិនដឹងគាត់ទៅណា មិនដឹងថាស្លាប់ មិនថារស់គេមិនឲ្យយើងដឹង ដេញដោលរឿងគេៗ យើងសុំតែម៉ារស់ៗម្នាក់ៗខ្លួនឯង រស់តែឪពុកម្តាយខ្លួនឯងក៏មិនអាចជួយបានសម័យនោះ ។

វណ្ណៈ : បាទ!ចុះអ្នក៧មេសាអី ម៉ោអីទៅធ្វើការនៅ ទៅលើកទំនប់ហ្នឹង?

រី : ធ្វើជាមួយគ្នាទាំងអស់ ទៅជាមួយគ្នា ។

វណ្ណៈ : អញ្ចឹងបើមីងគិតមើល ថាអ្នក១៧មេសានឹងអ្នកមូលដ្ឋាន តើការស្លាប់រស់ហ្នឹង ខាងណាមានអត្រាខ្ពស់ ដូចថាខាងណាមានស្លាប់ច្រើនជាង?

រី : បើអ្នកមូលដ្ឋានដូចមិនសូវស្លាប់ទេ ជាពិសេសគ្នាអ្នក១៧មេសា ព្រោះអីគ្នាម៉ោដូចថាគេសុទ្ធតែធូរធារ គេអ្នកមាន គេសាច់ឈាមគេល្អទៅ គ្នាមិនធ្លាប់ចុះប្រលូកនឹងការអត់ឃ្លាន ជួនកាលគ្នាឈឺទៅអត់ខ្វះជីវជាតិ គ្នាហើមភាគច្រើន ហើយធ្វើការហួសកម្លាំងទៀត បើពួកយើងអ្នកនេះទៅ យើងធ្លាប់ត្រូវថ្ងៃត្រូវនេះទៅចេះតែតស៊ូ រស់ៗទាំងត្រដរ ។

វណ្ណៈ : អញ្ចឹងភាគច្រើនសុទ្ធតែអ្នក១៧មេសាស្លាប់ច្រើន?

រី : ចា៎!

វណ្ណៈ : អញ្ចឹងពេលហ្នឹងមានដែលឃើញគេចាប់មនុស្សចាប់អីទេ?

រី : មីងអត់ដែលឃើញទេ អត់ដែលបានឃើញគេចាប់គេអី គ្រាន់តែ បើដឹកទៅពេទ្យទៅអីទៅមិនដែលថាយកម៉ោវិញ ឲ្យបានឃើញទេ បើឲ្យគេចាប់គេចងមិនដែលបាន ឃើញទេ ព្រោះអីគេធ្វើចោរគេធ្វើ តែយប់ ហើយយើងដែលយើងសោ (សោ = អស់កម្លាំង) យើងនឿយ យើងហត់ខ្លាំង យើងអត់ដែលមានពេលទេ ដល់ហើយជាពិសេសមិនដែលចាប់អារម្មណ៍នឹងអ្នកណាទៀត ព្រោះថាយើងគ្មានពេលនឹងគិត ពី រឿងអីអញ្ចឹងវាងប់ងល់អស់មិនដឹងថា គិតថា យ៉ាងម៉េច ដូចថាខ្វាក់ទាំងអស់ ដូចមិនដឹងអីទេ ដូចវាអស់កម្លាំងខ្លាំងទៅ វានឿយខ្លាំង ក្លួយហូបមិនឆ្អែត អីមិនឆ្អែត ទៅឲ្យតែរស់ៗវាប្រសើរហើយ ខ្លាចតែមិនរស់ទៀត ដល់ហើយមិនដែលមានអារម្មណ៍គិតពីអ្នកណាទៀត យើងគិតឃើញថាថ្ងៃណាយើង ងាប់ក៏ងាប់ទៅ មិនដឹងប្រាប់ថាម៉េច ។

វណ្ណៈ : អញ្ចឹងមីងបានដើរម៉ោលេងផ្ទះ ម៉ោលេងអីទេ?

រី ៖ អត់ដែលបានម៉ោទេ ។

វណ្ណៈ ៖ មីងមិនមានពេលម៉ោទាល់តែសោះ?

រី ៖ ចាំ! អត់មានពេលម៉ោទេ តាំងចាប់ពីថ្ងៃចេញចល័តទៅរហូត ។

វណ្ណៈ ៖ សុំគេក៏គេមិនឲ្យម៉ោដែរ?

រី ៖ ចាំ!គេមិនឲ្យម៉ោទេ ។

វណ្ណៈ ៖ ព្រោះគេការពារគេវាប្រញាឹក មួយថ្ងៃដឹងតែវាស់ថែម ។?

រី ៖ ចាំ!អត់ឲ្យម៉ោទេ សុំច្បាប់គេក៏គេមិនឲ្យម៉ោដែរ បើកអ្នកណាដែលម៉ោ បើអត់ច្បាប់លួចរត់ម៉ោអញ្ចឹង គេចាប់យកទៅវិញគេពិន័យទៅ គេពិន័យយើងដែលយើងរត់ខុសច្បាប់ហ្នឹងខុសអីហ្នឹង ម្លោះហើយអត់មានអ្នកណាហ៊ានរត់ទេ ចុះហ៊ានរត់អីខ្លាចងាប់ខ្លាចអីនោះចេះតែខ្លាច ចុះគេប្រើអំពើហិង្សាដាក់យើងនោះ ។

វណ្ណៈ ៖ បាទ!អញ្ចឹងសម្ភារៈដែលលើកទំនប់ហ្នឹង ក្នុងមួយនាក់គេចែកបង្គី១ ចប១ឬយ៉ាំង ម៉េច?

រី ៖ ក្នុង១នាក់ចប១ បង្គីម៉ាសម្រាប់ ដងវែកមួយសម្ភារៈ ។

វណ្ណៈ ៖ ចុះបើយើងវែកខូចបង្គី វែកបាក់បង្គីអញ្ចឹងគេឲ្យទៀត?

រី ៖ ចាំ!គេឲ្យទៀត ហើយមានអ្នកជុសជួល ដូចថាចបមានសណ្តក មានអ្នកបោះដងចប ឲ្យ ។

វណ្ណៈ ៖ អញ្ចឹងមានផ្នែក ។ ច្រើន?

រី ៖ ចាំ!មានប្រុសអញ្ចឹងម៉ាកង ម៉ាពួកយើងឆ្ងាយ ម៉ាក្រុមយើងចេះ ។ ទៅ មានប្រុសដើរបោះដងចបម្នាក់ បើនេះឃើញសណ្តកទៅគេទៅបោះឲ្យ នោះឃើញសណ្តកទៅបោះ ឲ្យ ។

វណ្ណៈ ៖ អញ្ចឹងបើយើងខូចសម្ភារៈអស់ហ្នឹង មានគេជួសជុលឲ្យ?

រី ៖ ចាំ!

វណ្ណៈ ៖ តែបើយើងខូចញឹកពេក គេរករឿងដែរឬអត់ បើយើងធ្វើបាត់ធ្វើអី?

រី ៖ មិនដែលមានណាបាត់ទេ ប្រុងប្រយ័ត្នរហូត ព្រោះខ្លាចអានោះឯងអាយុជីវិតយើង បើសិនយើងបាត់មិនមានហេតុផលទៅ គេយកទៅដាក់ទោសដែរ ដល់ហើយយើងត្រូវតែប្រើហើយថែរក្សា សឹងតែដេកក៏កើយបង្គីដែរ ចាំ!មែនដេកកើយបង្គី ពួកខ្ញុំរៀបបង្គីជល់គ្នា បានកើយ ។

វណ្ណៈ ៖ បាទ!អត់មានខ្នើយមានអីទេ?

រី ៖ អត់មានទេ ជួនកាលក៏កើយខោអាវយើងដែលយកទៅស្លៀកពាក់នោះឯង អត់មានថាឲ្យបាត់ទេ ។

វណ្ណៈ : ចុះខោអាវប៉ុន្មានខែគេបើកឲ្យយើងម្តង?

រី : ខោអាវទលតែរួចទំនប់ហ្នឹង បានគេបើកឲ្យយើងម៉ាកំផ្លេ ។

វណ្ណៈ : អ្ហូ!១ឆ្នាំនោះហ្នឹង?

រី : មិនដល់មួយឆ្នាំទេ លើកលឿនដែរ ប៉ុនគ្រាន់តែខ្ញុំអត់ដឹងថាចាប់ផ្តើមពីថ្ងៃណា ទីណា អត់ដឹងទេ ។

វណ្ណៈ : ចុះទំនប់ហ្នឹងថាកម្ពស់ប៉ុន្មានម៉ែត្រទៅ ហើយទទឹងទំនប់ហ្នឹងអាចបើកឡានបានទេឬក៏យ៉ាងម៉េច?

រី : កាលដែលលើករួចបើកឡានបាន ប៉ុនប៉ុន្មានម៉ែត្រខ្ពស់លើអត់ដឹងទេ ចេះតែរែកចាក់ៗ ប៉ុនហ្នឹង ។

វណ្ណៈ : ហើយចាប់ព័ន្ធពីខាងភូមិណាម៉ោភូមិណាមីងដឹងទេ?

រី : មីងអត់ដឹងទេ ព្រោះខ្សែត្រៀមដែលមីងលើកៗខាងស្ពានរាប ទៅណាទៀតគឺគេចេះតែដេញគ្នាទៅៗ ចេះតែម៉ារួចទៅៗទៅខាងណាំគៅ គេហៅគួកពទ្រៗ ព្រោះចេះណាំ!យើងរួចម៉ាចន្លោះទៅ គេដកយើងទៅនោះទៀត គេមានដឹងថាយើងហេវទេ ខាងស្រុកគេឆ្ងងទៅខាងនោះ ស្រុកយើងឆ្ងងទៅនោះបន្តៗគ្នា ។

វណ្ណៈ : ចុះស្រុកគេ មីងឃើញដូចថាស្រុកសេរីសោភ័ណម៉ោ មីងដែលនៅជិតគេដែរឬក៏នៅឆ្ងាយពីគ្នា?

រី : នៅជិតគ្នាដែរ ។

វណ្ណៈ : បាទ!ចុះសាច់ឈាមគេ ពេលម៉ោហ្នឹងគេមានសាច់ឈាមមាំជាងខាងព្រះនេត្រព្រះ ឬក៏ប្រហាក់ប្រហែលគ្នាឬក៏យ៉ាងម៉េច?

រី : ប្រហែលតែគ្នាហ្នឹង ធ្វើការដូចដែលគ្នា ។

វណ្ណៈ : ធ្វើការ ហូបចុក ហើយរបបដូចគ្នាអញ្ចឹង?

រី : ចាំ!ដូចគ្នាទាំងអស់ ។

វណ្ណៈ : អញ្ចឹង មិនមែនថាស្រុកណាៗទេ?

រី : អត់ទេ!សុទ្ធតែអត់ដូចតែគ្នា ព្រោះអីម៉ោវាយ៉ាប់ដូចតែគ្នាដែរ ។

វណ្ណៈ : ហើយព្ទថាសូប្បីតែទឹកក៏ខ្វះដែរយ៉ាងម៉េចមីង?

រី : ចាំ!ទឹកក៏ខ្វះអត់ដែលបានផ្ទួតទេ ។

វណ្ណៈ : បាទ!ហើយធ្វើយ៉ាងម៉េចទៅ ប៉ុន្មានថ្ងៃបានផ្ទួតមួយដង?

រី ៖ អត់មានផ្លូតរហូតទល់តែហើយទំនប់ហ្នឹង ។

វណ្ណៈ ៖ ចង់មួយឆ្នាំនោះ?

រី ៖ អត់រហូត អាវរហែកអស់ អត់បានផ្លូតទេ ចៃចេញតាមខ្លួនសុទ្ធតែចៃ អត់ដែលបានផ្លូតទេ ទឹកក៏អត់មានផ្លូតទៀតទឹក ទឹកឲ្យតែបានដឹកម្តងផង បើផ្លូតមិនបានផ្លូតទេ ។

វណ្ណៈ ៖ ដឹកមិនគ្រប់?

រី ៖ ចាំ!គ្រាន់តែហូបមិនគ្រប់ទេ ។

វណ្ណៈ ៖ ថាវាលំបែកគ្នាទៀត?

រី ៖ ចាំ!វាលស្លាប់ព្រា អាស្លាបព្រាបាយយើងហ្នឹង ។

វណ្ណៈ ៖ ចុះកាលទៅធ្វើទំនប់បានជិតមួយឆ្នាំហ្នឹង មីងមានបានកាន់ក្រុម កាន់កងអីទេ?

រី ៖ មីងអត់ដែលបានកាន់ទេ ។

វណ្ណៈ ៖ អញ្ចឹងប្រធានកាន់កងមីងឈ្មោះអីដែរ?

រី ៖ ប្រធានដែលកាន់កងមីងឈ្មោះ បងរស់ ។

វណ្ណៈ ៖ ឈ្មោះ រស់ សព្វថ្ងៃគាត់នៅរស់ទេ?

រី ៖ គាត់នៅ ។

វណ្ណៈ ៖ ប្រហែលប៉ុន្មាននាក់ គ្នាមីងហ្នឹង?

រី ៖ បងរស់ ហ្នឹងគាត់ក្តាប់កងរយទាំងអស់ ម៉ាក្នុងកងមីងនោះមិនដឹងថាអ្នកណាក្ងួចអស់មិនដឹងបងរ៉ាត់ ក៏មិនដឹង មិនដឹងបងរស់ ក៏មិនដឹងព្រោះអីពួកនោះស្លាប់អស់ទៅវិញ មីងក្ងួចអស់ ស្លាប់អស់ហើយពួកនោះ ម៉ាក្រុមគេកាន់ម្នាក់ ។

វណ្ណៈ ៖ រស់ៗ មួយណាមីង?

រី ៖ រស់ៗ បងរស់ ប្រធានកង ។

វណ្ណៈ ៖ ឥឡូវគាត់ធ្វើអីដែរ?

រី ៖ ធ្វើគ្រូនាយកសាលា ។

វណ្ណៈ ៖ អ៊ូលោកគ្រូ គីម រស់ ហ្នឹង?

រី ៖ ចាំ!

វណ្ណៈ ៖ គាត់កាចទេ?

រី ៖ ទេ!គាត់មិនជាកាច មិនជាអីទេធម្មតាៗ ។

វណ្ណៈ ៖ អ៊ូ!ខ្ញុំជួបគាត់ដែរ គាត់ថាពិបាកៗគាត់កើតចៃ កើតអីដែរគាត់?

រី : ចាំ!គាត់ដូចតែគ្នា គ្រាន់តែគាត់ក្តាប់យើងទៅ គេមិនពិបាកវែកដៃៗទេ ប៉ុន្តែអត់ទឹកដូតដូចគ្នាៗ ។

វណ្ណៈ : អញ្ចឹងគាត់មិនមែនអ្នកយកមនុស្សទៅសម្លាប់អីទេ?

រី : អត់ទេៗ!គាត់អត់ទេ ប៉ុនគាត់គេឲ្យក្តាប់បញ្ឈរ គាត់ក្តាប់ទៅគាត់រាងសម្តីទៅអីទៅ ។ គេប្រើគាត់ឲ្យគាត់ក្តាប់ទៅ ។

វណ្ណៈ : អញ្ចឹងគាត់អ្នកមើលការណ៍ខុសត្រូវ?

រី : ចាំ!ប៉ុនគាត់អត់ដូចគ្នា បាយអីគាត់ហូបរបបដូចយើងដែរ ។

វណ្ណៈ : ប៉ុន្តែគាត់ក្តាប់ គាត់ដើរមើលយើង គាត់ធូរជាងយើង យើងវែកគាត់អត់វែកទេ?

រី : ហ្នឹងហើយគាត់ងត់វែកទេ ប៉ុនគាត់កាចដូចមិនកាចទេ ដល់ពេលដូចជាអ្នកធំម៉ោអញ្ចឹងគាត់ស្តីឲ្យខ្លះទៅ ស្តីប៉ុនគាត់ស្តីបំបាត់ដានមិនឲ្យគេដឹងចិត្តទេ ។

វណ្ណៈ : អ្ហូ!អញ្ចឹងគាត់ស្លូតទេ?

រី : ស្លូត ។ បើសិនជាក្មួយឯងសួរអ្នកខាងភ្នំពេញច្រើនណាស់ អ្នកភ្នំពេញនៅជាមួយពួកខ្ញុំក៏ច្រើនដែរ ។

វណ្ណៈ : បាទ!ឥឡូវអ្នកភ្នំពេញគាត់ទៅស្រុកកំណើតវិញអស់ហើយ អត់មានអ្នកនៅនេះ?

រី : មានតែអ្នកនៅអារិយក្សត្រច្រើនណាស់ ក្មួយឯងទៅខាងអារិយក្សត្រច្រើនហ្នឹង មកលើកទំនប់អាងត្រពាំងថ្ម ព្រោះនៅជាមួយខ្ញុំច្រើនណាស់អ្នកអារិយក្សត្រ ។

វណ្ណៈ : បាទ!អត់អីទេ ចាំខ្ញុំហៅគេឆ្លងទៅអារិយក្សត្រសម្ភាសន៍ទៀត ។

រី : ចាំ!ព្រោះអារិយក្សត្រធ្វើអាងត្រពាំងថ្មក៏ច្រើន ម៉ាជួរភ្នំពេញហ្នឹង ប៉ុនពួកនោះខ្លាចគេទៅអាមេរិចអស់ ពួកមិត្តភក្រ្តខ្ញុំហ្នឹងក៏ច្រើនដែរ ។

វណ្ណៈ : ឥឡូវគេអត់ដែលមកលេងទេ?

រី : អត់ដេលមកលេងទេ ប៉ុនតាមមើលគេទៅអាមេរិចអស់ហើយ ប៉ុនតែពួកនៅអារិយក្សត្រដឹងតែនៅ ព្រោះកាលប៉ុន្មានឆ្នាំមុនវាម៉ោដាក់កឋិននៅនេះ សុទ្ធតែពួកចល័តជាមួយពួកខ្ញុំ ។

វណ្ណៈ : ចុះស្គាល់មីងឆាតទេ?

រី : មីងឆាតទេខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ : មីង រស់ គាត់ស្គាល់ ពួកម៉ាកមីងរស់ បងឆាត នៅអារិយក្សត្រ ។

រី : ចាំ!

វណ្ណៈ : អញ្ចឹងខ្ញុំសួរទាក់ទងនៅសម័យខ្មែរក្រហមវិញ ពី៧៥ដល់៧៩ហ្នឹង អញ្ចឹងកាលដែលធ្វើទំនប់នៅអាងត្រពាំងថ្មហ្នឹងមីងដែលឃើញ តាវ៉ាល់ អីទៅបញ្ជាទៅអីទេ តាវ៉ាល់ តាម៉ោងអី?

រី : តាវ៉ាល់ឃើញ បើតាម៉ោងអត់ដែលឃើញទេ ហើយជាពិសេសដែលមីងឃើញខ្លាំងជាងគេតាសំអាត។ ហ្នឹងគាត់នៅក្ដាប់មីងនៅដើមគរ៣ដើមនេះគាត់ក្ដាប់ជាប់ តែម៉ោពីអាងត្រពាំងថ្ម គាត់ក្ដាប់ជាប់រហូតមកដល់ដើមគរ៣ដើម ប៉ុន្តែនៅកន្លែងទំនប់តាវ៉ាល់នោះ អាងត្រពាំងថ្មនេះ អត់ដែលឃើញតាវ៉ាល់ទេ អត់សូវស្គាល់គាត់ទេ។

វណ្ណៈ : បាទ!តាមដឹង តាមមីង រស់និយាយថាតាវ៉ាល់ គាត់ទៅកាន់កាប់ហ្នឹង?

រី : ចា៎!ប៉ុនគាត់ប្រធានអញ្ចឹង គាត់បានប្រជុំនេះ ដូចមីងប្រជាជនឲ្យតែល្ងាចហើយ មីងចូលរោងហើយ ព្រោះទៅយកកម្លាំងវែកដី វែកទាំងយប់វែកទាំងថ្ងៃ មិនដែលបានចាប់អារម្មណ៍ មិនដែលបានឃើញគាត់ទេ បើពួកគេអ្នកប្រធានគេប្រជុំជាប់រហូតរឿងអីគេមិនស្គាល់ នោះគេជិតជិតជាងយើង។

វណ្ណៈ : បាទ!ចុះមីងដឹងថាពួកនិរតីម៉ោ កាន់កាប់គ្រប់គ្រងជំនួសតាវ៉ាល់ តាម៉ោងអីវិញហ្នឹងថាឆ្នាំណា មីងចាំឆ្នាំទេ?

រី : មីងអត់ចាំទេ គ្រាន់តែមីងម៉ោពីអាងត្រពាំងថ្មវិញ មីងម៉ោនៅប្រពន្ធ័ប្រឡាយគេហៅគរ៣ដើម នោះបានឃើញពួកនិរតីម៉ោ ម៉ោហ្នឹងទល់តែលើកអាងត្រពាំងថ្មហើយ បើនៅអាងត្រពាំងថ្មគឺ ពាយ័ព្យហ្នឹងឯងកាន់កាប់។

វណ្ណៈ : ចុះឮថាអាងត្រពាំងថ្មហ្នឹងមានតាវ៉ាល់ តាម៉ោង ក្រោយម៉ោគេចាប់តាម៉ោង តាក្រកអីទៅបាត់អញ្ចឹង កាលហ្នឹងមីងមានដឹងថាគេចាប់?

រី : មីងអត់ដឹងទេ គ្រាន់តែឃើញនិរតីម៉ោក៏ម៉ោ មិនបានថាអ្នកណាចាប់អ្នកណាគេ អត់ឲ្យយើងប្រជាជនដឹងទេ គ្រាន់តែគេផ្លាស់អ្នកម៉ោបញ្ជាយើងទេ គ្រាន់តែដឹងថាប្លែកពេលនេះឃើញអ្នកផ្សេង ពេលនោះឃើញអ្នកផ្សេង តែត្រង់រឿងហេតុអីគេអត់ដឹងទេ។

វណ្ណៈ : អញ្ចឹងដូចថាពេលចាប់ពួកពាយ័ព្យទៅអស់អញ្ចឹង ដូចជា តាក្រក តាវ៉ាល់ តាមៅ៉ងអីអញ្ចឹងទៅអស់ទៅ តើពួកអ្នកនិរតីម៉ោហ្នឹង ប្រជាជនបានសុខសប្បាយជាងមុនឬក៏រឹតតែមានការលំបាកខ្លាំងទៅៗ?

រី : នៅតែប្រើ វាល់បាយ ការងារអីនៅធ្វើខ្លាំងតែដដែលអញ្ចឹង អត់ដែលបន្ធូរបន្ថយ ទេ។

វណ្ណៈ : ចុះការសម្រាប់វិញយ៉ាងម៉េចដែរ?

រី ៖ បើក្នុងកន្លែងអន្តរាគមន៍នេះ អត់មានសម្លាប់ទេ ឃើញតែស្លាប់នឹងជំងឺទេ បើសិនជាយកចង់ទៅសម្លាប់អត់មានទេ មីងនៅអន្តរាគមន៍មីងដែលនៅ ចេញម៉ោពីអាងត្រពាំងថ្មវិញ ម៉ោតាមចង្កេះគរ៣ដើម ។

វណ្ណៈ ៖ កងមីងរស់ហ្នឹង?

រី ៖ ចាំ! អត់មានថាអ្នកណា បើថាឈឺស្លាប់មាន ដូចថាឈឺអត់បាយអត់អីទៅ ទារុណទារាទៅស្លាប់មាន បើថាចង់យកទៅវៃទៅអីមីងអត់ដែលឃើញទេ ព្រោះមិនដឹងថាគេយកទៅស្នាលណាអីស្នាលណី ហើយដូចថាយើងជាប្រជាជន យើងអត់បានដឹងថាអ្នកនេះប៉ុននេះ អ្នកនោះប៉ុននោះអីទេ អ្នកណាបាត់ទៅណាយើងក៏គ្មានសិទ្ធដឹងទេ បាត់ទៅណាក៏បាត់ទៅ បើគេគ្រាន់តែថា អង្គការឲ្យទៅរៀន ដឹងតែទៅណាយើងក៏មិនដឹង មីងអត់ហ៊ានសួរគេទេ ។

វណ្ណៈ ៖ ចុះមីងឧទាហរណ៍ថា យើងឧបមាថាឲ្យ២ម៉ែត្រគីបក្នុង១ថ្ងៃ ចុះបើយើងធ្វើអត់ហើយគិតយ៉ាងម៉េច?

រី ៖ យើងធ្វើអត់ហើយ គេក៏អត់ឲ្យបាយយើងហូប យើងប្រឹងទាល់តែហើយ ។

វណ្ណៈ ៖ ចុះឧបមាថាឥឡូវយើងអត់ហើយ យើងឈប់ទៅញ៉ាំបាយជាមួយគេសិន ហើយយើងឆ្លៀតម៉ោធ្វើទៀត?

រី ៖ បាន ក៏ប៉ុន្តែយើងអត់មានពេលសម្រាក គេឲ្យសម្រាកម៉ោង១២ ម៉ោង១២យើងឆ្លៀតទៅញ៉ាំបាយហើយ យើងត្រឡប់ម៉ោវិញ យើងត្រូវតែរែកដីរហូតទាល់តែរួចរួចពាគីបហ្នឹងទៅ បានយើងបានទៅដែរ ។

វណ្ណៈ ៖ បានយើងឡើងទៅសម្រាកដែរ?

រី ៖ ចាំៗ! ៣ម៉ែត្រគេរួចមុនគេឡើងមុន អ្នកណារួចក្រោយគេឡើងក្រោយ បើយើងមិនរួចទេយើងធ្វើឲ្យរួច ។

វណ្ណៈ ៖ ចុះឧបមាថា ដូចថាយើងមានពួកម៉ាកយើង យើងអាចទៅជួយគ្នាបានទេ?

រី ៖ អត់បានទេ ។

វណ្ណៈ ៖ អត់បានទេ អង្គការឃើញអត់បានទេ?

រី ៖ បើឃើញគេកាន់តែថែមម៉ែត្រគីបឲ្យអ្នកដែលជួយ ដូចឧទាហរណ៍ថា ខ្ញុំធ្វើអត់រួចក្មួយឯងមកជួយខ្ញុំ ដល់ជួយថ្ងៃក្រោយទៀត ឃើញអ្នកនោះមានកម្លាំងមកជួយចេះគេបន្ថែមម៉ែត្រគីបឲ្យអ្នកដែលជួយ រហូតអត់ហ៊ានជួយគ្នាទេ ។

វណ្ណៈ ៖ អញ្ចឹងអត់មានពីណាជួយពីណាទេ?

រី ៖ អត់ហ៊ានជួយទេ ពីណាធ្វើមិនរួចក៏សុខចិត្តដើរចេញទៅ សូម្បីតែបងប្អូនបង្កើតក៏សុខចិត្តតែ ជួយដែរបងប្អូនបង្កើតជួយទាំងលួចលាក់ ។

វណ្ណៈ ៖ អញ្ចឹងខ្លះគេថាខាងនិរតីម៉ោ ដូចយាយថែម យាយអីម៉ោហ្នឹង សម័យហ្នឹងនៅអាងត្រពាំងថ្មនៅមានលើក អញ្ចឹងគិតថាពួកហ្នឹងអត់ទាន់ម៉ោទេ តាមពិតយាយថែម គេថាម៉ោខែ៩ ៧៧?

រី ៖ យាយថែម ម៉ោចប់ហើយ ព្រោះខ្ញុំម៉ោនៅគរ៣ដើមនេះ គេហៅគរ៣ដើម នោះខ្ញុំចេញពីអាងត្រពាំងថ្មម៉ោ បានឃើញពួកនិរតីម៉ោក្តាប់ខ្ញុំ ប៉ុន្តែមិនដឹងថាគេម៉ោមុនពីស្មាលណាក៏ខ្ញុំមិនដឹង ព្រោះដឹងតែពេលនោះខ្ញុំចេញម៉ោពីនោះហើយ ចេញម៉ោបានផ្លាស់ពួកបងទា បងយន នោះពួកនិរតី នោះគាត់ចុះមកក្តាប់ខ្ញុំផ្ទាល់ទាំងអស់ នោះខ្ញុំស្គាល់ពួកគាត់ច្បាស់ ។

វណ្ណៈ ៖ ចុះដូចជានៅអាងត្រពាំងថ្មហ្នឹងដែរ ចុះមានពេទ្យមានអីព្យាបាលតាមអ្នកនៅកងចល័តហ្នឹងប៉ុអត់?

រី ៖ ពេទ្យមានហើយក្មួយ តែពេទ្យដូចមិនមែនពេទ្យ ចុះបើពេទ្យប្រជាជនយើងនោះឯងមិនបានរៀនសូត្រទៅធ្វើជាពេទ្យ មិនដឹងថាមានអីស្អីទេ ឈឺក្បាលកើតគ្រុនមិនដឹងថាមានថ្នាំអីទេ អត់ មានតែគេសូន្យដើមឈើយើងហ្នឹង ដាក់ទឹកឃ្មុំដាក់អីយកទៅឲ្យទៅបើថ្នាំបារាំងថ្នាំអីអត់ឃើញទេ ដូចមិនដែលបាន ឈឺក៏មិនដែលបានហូបបានអីដែរអត់រហូត ។

វណ្ណៈ ៖ បាទ!មីងគិតមើល៍ មីងស្រមៃមើលថាអាងត្រពាំងថ្ម មានមនុស្សមើលទៅរាប់គីឡូដី ប្តុក៏បើសិនជាយើងគិតជាចំនួនមនុស្សវិញវាអាចរាប់ម៉ឺន រាប់ពាន់នាក់?

រី ៖ ចា៎! រាប់គីឡូដីឃើញតែមនុស្ស ឲ្យតែភ្លឺឡើងមើលទៅលើខ្នងទំនប់ម្តងៗ មើលទៅសុទ្ធតែមនុស្សមរមី ។

វណ្ណៈ ៖ ខ្មៅ?

រី ៖ ចា៎! ខ្មៅទទួក ។

វណ្ណៈ ៖ ស្លៀកខោអាវខ្មៅទាំងអស់គ្នា?

រី ៖ ចា៎!ខ្មៅទាំងអស់ មើលទៅឡើងខ្មៅ ។

វណ្ណៈ ៖ បាទ!មនុស្សប្រហែលជាប៉ុន្មានទៅ បើតាមមីងគិត?

រី ៖ អ៊ូ! រាប់ពាន់នាក់ មិនតិចទេច្រើនណាស់ ។

វណ្ណៈ ៖ កាលហ្នឹងអ្នកដែលទៅលើកហ្នឹងយកយុវជន យុវនារី អត់មានយកអ្នកកសិករអីមានកូនមានចៅអីទៅលើក?

រី ៖ អត់យកទេ យកតែយុវជន នារីសុទ្ធ ។

វណ្ណៈ ៖ បាទ!អញ្ចឹងពេលរោងដេកហ្នឹង ដល់ពេលធ្វើរោងហើយគេមានដាក់គ្រែ ដាក់អីទេ?

រី ៖ អត់ទេ ដេកនឹងដីផ្ទាល់ ។

វណ្ណៈ ៖ អត់មានគ្រែដេក?

រី ៖ អត់មានទេ គ្រាន់តែយើងបាំងរោងពីលើ ខ្លាចមេឃភ្លៀង ឬក៏យើងត្រូវសម្រាកថ្ងៃដែលយើងត្រូវមកហូបបាយ តែគ្រែគ្មានទេ ដេកផ្ទាល់នឹងដី ។

វណ្ណៈ ៖ ដេកផ្ទាល់ដី?

រី ៖ ចា៎! ដេកផ្ទាល់ដី គ្រាន់តែយើងក្រាល ដូចថាយើងយកកន្ទេល យកអីទៅខ្លួនយើងស្ពាយយកទៅឬក៏ដូចថា ដាក់កៅស៊ូយកទៅក្រាលដេកខ្លួនឯង អត់មានកន្ទេលអត់មានអីទេ ប៉ុនយើងយកពីផ្ទះទៅខ្លួនឯង ។

វណ្ណៈ ៖ ចុះមីងដែលឃើញមនុស្សដេកៗ ព្រលឹមឡើងមានស្លាប់មានទេ?

រី ៖ ទេ! នៅកន្លែងអគ្គភាពមីងអត់ដែលមានទេ បើផ្សេងៗ ជាពិសេសអាដេកស្លាប់ហ្នឹងច្រើនតែពួកខាងយុវជន ដែលធ្វើការខ្លាំងៗជាងនារីទៀត ។

វណ្ណៈ ៖ អ៊ូ!យុវជនស្លាប់ច្រើនជាងនារី?

រី ៖ អ្នកធ្វើការខ្លាំងជាងនារី ប៉ុនខាងមីងអត់ដែលមានឃើញដេកស្លាប់ដេកអីទេ អត់មានទេបើពួកយុវជនធ្វើការខ្លាំងជាងនារី ។

វណ្ណៈ ៖ អញ្ចឹងធ្វើការធ្ងន់ជាង?

រី ៖ ចា៎! ធ្ងន់ជាង ខ្លាំងជាង ព្រោះប្រុស៣ម៉ែត្រគីប ចាប់ពី៣ម៉ែត្រគីបកន្លះឡើងទៅ ៦ម៉ែត្រគីប ។

វណ្ណៈ ៖ អ៊ូ! ៦ម៉ែត្រគីបគេដាក់ទណ្ឌកម្មទេអាហ្នឹងអី?

រី ៖ ចា៎! វាដូចតែទណ្ឌកម្មរហូតសម័យហ្នឹង មួយថ្ងៃៗសុទ្ធតែទណ្ឌកម្ម ។

វណ្ណៈ ៖ ចុះមានថ្ងៃឈប់សម្រាកដែរឬអត់?

រី ៖ អត់មានទេ នៅលើកអាងត្រពាំងថ្មអត់មានថ្ងៃឈប់សម្រាកទេ លើករហូត ។

វណ្ណៈ ៖ អត់មានមាអាទិត្យអី ឈប់មាថ្ងៃអីអត់ទេ?

រី ៖ អត់ទេ! អត់មានទេ បើសម្រាកអីគេឲ្យសម្រាកតែពួកប្រធានកង ប្រធានក្រុមគេប្រ ជុំ បើយើងប្រជាជនអត់ដែលមានពុសម្រាកទេ រួចទៅទទេ ។

វណ្ណៈ ៖ បាទ!ចុះមីងចប់អាងត្រពាំងថ្មឆ្នាំណា?

រី ៖ មិនដឹងឆ្នាំណាទេ អត់ចាំទេ ។

វណ្ណៈ ៖ បើចប់អាងត្រពាំងថ្ម ចប់នៅខែប្រាំងឬខែវស្សា?

រី ៖ ចប់ខែវស្សា ចប់បែបខែ៥ខែអីហ្នឹងឯង ចប់អាងត្រពាំងថ្ម ព្រោះអីមីងចប់អាង ត្រពាំងថ្មភ្លាមម៉ោដើមគរ៣ដើម បាន៣ថ្ងៃទៅភ្លៀងរហូត ដឹងតែចប់ខែ៥ហ្នឹងឯង ព្រោះមកដល់ដើមគរ៣ដើមនេះគេឲ្យ ។

វណ្ណៈ ៖ ខែ៥ នៅឆ្នាំណា?

រី ៖ មិនដឹងឆ្នាំណាទេ អត់ចាំទេ ។

វណ្ណៈ ៖ ពេលចប់អាងត្រពាំងថ្មមហើយ បានប៉ុន្មានឆ្នាំទៀតណាមចូលម៉ោ?

រី ៖ ចប់អាងត្រពាំងថ្មបាន១ឆ្នាំ ។

វណ្ណៈ ៖ អញ្ចឹងប្រហែល៧៨?

រី ៖ ចាំ!៧៨ បានមួយឆ្នាំបានយួនចូល ។

វណ្ណៈ ៖ អញ្ចឹងបន្ទាប់ពីចប់អាងត្រពាំងថ្មហ្នឹង មីងម៉ោធ្វើទំនប់ណាទៀត ទំនប់អីគេ?

រី ៖ មីងម៉ោនៅដើមគរ៣ដើម?

វណ្ណៈ ៖ ទំនប់ដើមគរ៣ដើម?

រី ៖ ចាំ!

វណ្ណៈ ៖ ដើមពោធិ៍ ឬដើមគរ?

រី ៖ ដើមគរ៣ដើម ។

វណ្ណៈ ៖ អាហ្នឹងទំនប់សម្រាប់ធ្វើដែរ?

រី ៖ អត់មានទំនប់ទេ ប្រពន្ធ័ប្រឡាយធ្វើជាស្រែ ប្រព័ន្ធភ្លឺស្រែ ម៉ោលើកភ្លឺស្រែគេហៅ ប្រព័ន្ធភ្លឺស្រែ ។

វណ្ណៈ ៖ ប្រពន្ធ័ភ្លឺស្រែ?

រី ៖ ចាំ! ស្ទូងដក ច្រូត នៅដើមគរ៣ដើមហ្នឹងរហូតម៉ោ ។

វណ្ណៈ ៖ ប្រពន្ធ័ភ្លឺស្រែសម្រាប់ស្តុកទឹក?

រី ៖ ចាំ! សម្រាប់ស្តុកទឹកៗ គ្រាន់ប្រចេញប្រចូលទឹក ធ្វើស្រូវប្រាំងផង ស្រូវវស្សា ផង ។

វណ្ណៈ : អញ្ចឹងអាងត្រពាំងថ្ម ក៏ស្តុកទឹកទុកដូចគ្នា?

រី : ចា៎! ស្តុកទឹកដូចគ្នា ប៉ុន្តែប្រព័ន្ធភ្លឺតូចៗណាក្មួយ ប្រពន្ធ័ភ្លឺតូចៗគ្រាន់តែធ្វើស្រែប្រាំង ទៅយើងស្តុកទឹកទុកទៅ ហើយធ្វើស្រែរហូតទាំងប្រាំង ទាំងវស្សា ។

វណ្ណៈ : ចុះបើមានមនុស្សរាប់ម៉ឺននាក់ទៅធ្វើអាងត្រពាំងថ្ម ឬក៏នៅប្រព័ណ្ឌប្រឡាយនៅដើមគរ ៣ដើមអីអញ្ចឹង តើមានប្រជាជននៅក្នុងភូមិហ្នឹងគាត់បន្តបង្កើនផលបានច្រើនទេ ធ្វើស្រូវធ្វើអី?

រី : មីងនៅអត់មានប្រជាជនទេតាមវាល ។

វណ្ណៈ : ចុះមីងអត់ដឹងថា ខាងក្រោមនេះគេមានធ្វើស្រូវ ធ្វើអីទេ នៅក្នុងភូមិនេះមីងអត់បាន ដឹងទេ?

រី : អត់បានដឹងទេ ព្រោះអីមីងនៅតែតាមវាលរហូត អត់ដែលបានចូលភូមិចូលស្រុកទេ ។

វណ្ណៈ : បាទ!អញ្ចឹងមីងនៅក្នុងអំឡុងពេលហ្នឹង ពេលមីងនៅអាងត្រពាំងថ្ម នៅដើមគរ៣ដើម អីហ្នឹងពេលហ្នឹង គេមានដូចថា អង្គការមានដង្វំផ្តុំដូចថា ចាប់ឲ្យយើងរើសគូររៀប ការមានទេ?

រី : មីងនៅនោះអត់ដែលមានផង គ្មានអ្នកណាផ្សំផ្គុំអីទេដូចថា កន្លែងនោះមិនសូវមានអ្នក ណាស្រឡាញ់អ្នកណាអីណីទេ ព្រោះវាពិបាកពេកទៅ ហើយនៅឆ្ងាយដាច់ពីភូមិទៀត អត់មានទេ ។

វណ្ណៈ : បាទ!អត់ទេ?

រី : ចា៎!

វណ្ណៈ : ចុះមីងការៗក្រោយ៧៩ទៀត?

រី : ការក្រោយ៧៩ទេ សម័យវៀតណាម ។

វណ្ណៈ : អញ្ចឹងមីងៗធ្វើនៅដើមគរ៣ដើមហ្នឹង ដល់ឆ្នាំ៧៩វៀតណាមចូលតែម្តង?

រី : ចា៎! ធ្វើរហូត ទាល់តែថ្ងៃវៀតណាមចូលម៉ោ ក៏រត់ទៅផ្ទះ ។

វណ្ណៈ : ពេលមីងរត់ទៅផ្ទះមានគ្នាច្រើនទេកាលហ្នឹង?

រី : ម៉ោគ្នាច្រើនដែរ ប៉ុនដឹងថាខាងអង្គភាពណាៗ ដើររហូតសុទ្ធតែមនុស្សគេក៏ម៉ោ យើង ក៏ម៉ោ មានអ្នកទៅមានអ្នកម៉ោ ដើរម៉ោរហូត មនុស្សរហូតមិនចេះអស់ទេ ជាប់តាម ផ្លូវម៉ោរហូតម៉ោ ។

វណ្ណៈ : អញ្ចឹងនៅកន្លែងអន្តភាពចល័តរបស់មីងហ្នឹង ម៉ាចំនួនទៀតមានគេរត់ទៅខាងជាយរត់ទៅខាងអីមានទេមីង?

រី : មីងអត់ដឹងទេ ព្រោះដឹងតែគេប្រកាស៧មករា ភ្លាមក៏ចេញម៉ោ មីងក៏ទៅខាងភូមិមីង គេក៏ទៅខាងភូមិគេ មិនដឹងថាអ្នកណាទៅៗមីងអត់ដឹងទេ ព្រោះអីរវបានម៉ោផ្ទះវិញ នាំគ្នារត់ម៉ោតំរង់រកតែផ្លូវម៉ោផ្ទះ មិនដឹងថាអ្នកណាទៅអ្នកណាទៅណាអីអត់បានដឹងទេ ។

វណ្ណៈ : ចុះមីងម៉ោដល់ភូមិស្រុកវិញ មីងរៀបការឆ្នាំណាដែរ?

រី : រៀបការឆ្នាំ៨១ ។

វណ្ណៈ : ឆ្នាំ៨១ យើងកាលហ្នឹងអត់ទាន់មានលុយទេ យើងចងដៃអន្ទរ ចងដៃអីទេ?

រី : ចាំ!

វណ្ណៈ : ហើយកាលហ្នឹងមានតុ?

រី : មានតុ ដូចនៅតាមសាលារៀន ។

វណ្ណៈ : ហើយមានភ្លេងការ ភ្លេងប្រពៃណី?

រី : អត់ទាន់មានទេ ប៉ុនមានមេក្រូប៉ុនយើងចាក់កាសែត្រ មីងការឆ្នាំ៨២ហើយ ។

វណ្ណៈ : នៅស្រុកភូមិនេះ ពេលក្រោយវៀតណាមចូលម៉ោអញ្ចឹង មីងដូចថាពួកខ្មែរក្រហមអីចូលអុកឡុកក្នុងភូមិហ្នឹងទៀតទេ?

រី : ចូលក្តួយៗ ។

វណ្ណៈ : នៅនេះមានចូលមានអីដែរ?

រី : ចាំ! ចូលរករឿងរត់ ប៉ុន្តែប្រជាជននៅភូមិនេះអត់មានអ្នកណាហ៊ានដេកភូមិទេ ។

វណ្ណៈ : អញ្ចឹង អាក្រោយវៀតណាមចូលហើយហ្នឹង?

រី : ចាំៗ!

វណ្ណៈ : អញ្ចឹងវៀតណាមចូល ឧបមាថាវៀតណាមចូលដល់ក្នុងភូមិអញ្ចឹង ខ្មែរក្រហមរត់ទៅដល់ពេលវៀតណាមដកចេញ?

រី : វាចូលមកម្តង ។

វណ្ណៈ : អញ្ចឹងក្រោយ៧៩ម៉ោហ្នឹង នៅក្នុងស្រុក ភូមិនៅមានរង់គ្រោះទៀត?

រី : នៅតែរត់ៗ រត់ខ្លាចវាៗចេះតែថាដូចថា វាមានពាក្យឃោសនាវាអាករចោលស្អីៗ ទៅសម្លាប់តែកូនក្នុងអង្រឹងមិនទុក អញ្ចឹងមិនរត់ អត់ដែលហ៊ាននៅភូមិទេ ។

វណ្ណៈ : អញ្ចឹងអត់សូវបានរកស៊ីអី ធ្វើស្រែអីម៉េចទៅ?

រី ៖ អត់ទេ ។

វណ្ណៈ ៖ ក្រោយ៧៩ហ្នឹងក៏ពិបាកទៀត?

រី ៖ នៅពិបាកទៀត ទាល់តែគេយកទ័ពយកអីម៉ោដាក់ វៀតណាមម៉ោនៅក្នុងភូមិទៅបានរស់ហ្នឹងខ្លួនវិញ បានធ្វើស្រែធ្វើអីស្រួលវិញ ។

វណ្ណៈ ៖ ដល់ឆ្នាំណាបានស្រួលខ្មែរក្រហមលែងឡើងម៉ោដល់ហ្នឹង?

រី ៖ ចាប់ពីឆ្នាំ៨៣-៨៤ម៉ោគឺថាស្រួលរហូតហ្មង ស្រួលរហូតបានធ្វើស្រែធ្វើអីស្រួលឈប់រត់ឈប់លូនហើយ ។

វណ្ណៈ ៖ អញ្ចឹងខ្ញុំជិតអស់សំនួរហើយ ខ្ញុំសួរមីងទាក់ទងនឹងតុលាការបន្តិច មីងសព្វថ្ងៃមានដឹងថាមានការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរឬអត់?

រី ៖ មីងដឹង ឮគេផ្សាយតាមទូរទស្សន៍ ។

វណ្ណៈ ៖ មីងយល់យ៉ាងម៉េចដែរការកាត់ទោសហ្នឹង កាត់ទោសមេដឹកនាំខ្មែរក្រហមមីងយល់យ៉ាងម៉េចដែរមីង មីងគិតថាការកាត់ទោសហ្នឹង ជាការត្រឹមត្រូវដើម្បីរកយុត្តិធម៌ឲ្យជនរងគ្រោះ ឬក៏មិនត្រឹមត្រូវទេ ការកាត់ទោសមេដឹកនាំខ្មែរក្រហមដូចជា អៀង សារី នួន ជា ខៀវ សំផនអីអញ្ចឹងមីង?

រី ៖ តាមអារម្មណ៍មីង បើថាកាត់ទោសអញ្ចឹងដូចមិនអស់ចិត្ត វាធ្វើបាប ចង់តែសម្លាប់ភ្លាមៗ ។

វណ្ណៈ ៖ កាត់ទោសហើយមិនអស់ចិត្តទៀត?

រី ៖ មិនអស់ចិត្តទេ ព្រោះវាធ្វើបាបខ្លាំងណាស់ពេក យើងស្លាប់យើងវេទនាហើយ វាកាត់ទោសវាចេះតែរួចខ្លួនទៅ ខ្លួនវាមួយថ្ងៃជាមួយថ្ងៃវាចេះតែសម្រាលបានទៅ ដល់យើអវេទនានោះ វេទនាតែរហូតមិនដែលមានពេលស្រាកស្រាម រយៈពេល៣ឆ្នាំនេះវេទនាណាស់ វាសព្វថ្ងៃវាត្រឹមតែកាត់ទោសៗ វាចេះខ្លួនវាស្រួលមិនដូចយើងណាវាដេកបានវាស៊ីបាន ។ ចុះកាលវាធ្វើបាបយើង វាធ្វើដាក់កំរិតយើង តាមតែចិត្តវា ធ្វើដល់ដាក់ទៅវានេះវាស្រួលទៅ វាបានស៊ីវាបានដេក វាមិនទៅលំបាកដូចយើង ណា ។

វណ្ណៈ ៖ សម័យកាលវាខុសគ្នា កាលសម័យខ្មែរក្រហមហ្នឹងគឺ ជាពិសេសវាបិទមិនឲ្យសហគមអន្តរជាតិចូលម៉ោច្រើនទេ គឺមានតែប្រទេសកុម្មុយនីស្តមួយចំនួនមីង ដូច្នេះវាធ្វើការងារអីក៏ដោយ ខ្មែរក្រហមវាអត់បានជំនុំជំរះក្តីអីទេ គឺចង់សម្លាប់អ្នកណាចោទអ្នកណាគឺយកទៅសម្លាប់ អត់បានយកទៅកាត់ទោសដូចសម័យឥឡូវទេ ហើយបើថាសម័យ

យើងនេះស្រុកគេដូចថា សន្តិភាព ប៉ុន្តែមានប្រទេសជាច្រើនបានចូលមកក្នុងប្រទេសយើងអញ្ចឹង ហើយយើងមានច្បាប់ទម្លាប់អន្តរជាតិអីអញ្ចឹងទៅ អញ្ចឹងការកាត់ទោសវាត្រូវមានដូចថា ត្រូវមានការស៊ើបអង្កេត ត្រូវមានមេធាវីទាំងខាង អត់បានយកមនុស្សទៅសម្លាប់ទេ ដូច្នេះការទាមទារការកាត់ទោសហ្នឹងវាមានលក្ខណៈយូរ ហើយដើម្បីឲ្យមានយុត្តិធម៌ទាំងអស់គ្នា អញ្ចឹងយើងមានច្បាប់យើងត្រូវថា ទោះបីដឹងថាគាត់ធ្វើបាបប្រជាជនរយៈ៣ឆ្នាំមែន ប៉ុន្តែគេនៅតែនឹងរកមេធាវីការពារឲ្យគាត់ដែរដើម្បីឲ្យមានយុត្តិធម៌ វាខុសពីរបបគាត់កាន់កាប់ អញ្ចឹងមីងនិយាយក៏ត្រូវម្យ៉ាងដែរ ព្រោះគាត់គិតថា គាត់ជាប់ទោសសម័យនេះគាត់ហូបចុកដេកស្រួល ហើយការជាប់គុកកាលសម័យគាត់ អ្នកជាប់គុកគ្មានសង្ឃឹមថារស់ទេ ហើយពិបាកវេទនា ដឹងតែស្លាប់ ។

រី : ចា៎! កុំថាតែអ្នកជាប់គុក គ្រាន់តែយើងប្រជាជនវាប្រើយើង ក៏វាប្រើហួសពីអ្នកជាប់គុកទៅទៀត អ្នកជាប់គុកសម័យនេះស្រួលជាងសម័យនោះ អ្នកជាប់គុកសម័យនេះស្រួលជាងពួកយើងអ្នកធ្វើការសម័យនោះ ។

វណ្ណៈ : បាទៗ! អញ្ចឹងមីងខ្ញុំអរគុណច្រើនដែលបានផ្តល់បទសម្ភាសន៍?

រី : ចា៎ៗ!

«ចប់»